កសិកម្មនិរន្តរភាព

ឆ្នាំ២០១៦

# បច្ចេកទេសផលិតជី កំប៉ុស្តគោក

## សារៈប្រយោជន៏៖

- ជួយអោយដំណាំលូតលាស់ មានសុខភាពល្អ និង ចូលរួមថែរក្សាបរិស្ថាន
- មិនប៉ះពាល់ដល់សុខភាពអ្នកផលិតនិង អ្នកបរិភោគ
- បង្កើនទិន្នផល និង លើកកំពស់ប្រាក់ចំណូលគ្រួសារ កសិករអាចផលិតបានដោយខ្លួនឯង
- ប្រើប្រាស់ធនធានដែលមាននៅក្នុងសហគមន៏បង្កើនគុណភាពដី និង ធ្វើអោយដីផុសល្អ។

### ១. វត្ថុធាតុផ្សំ:

១. អង្កាមរស់ចំនួន៥០០គ.ក

២. ក្បាលត្រី/ខ្យងមាស ចំនួន ២០០គ.ក

៣. ធ្យូងអង្កាមចំនួន ៥០០គ.ក

៤.លាមក មាន់/ទា/ គោចំនួន ១០០០គ.ក

និងលាមកប្រចៀវចំនួន ២០គ.ក

៥. កន្ទក់ចំនួន១០០ទៅ ២០០គ.ក

៥.មេជីទឹកធម្មជាតិចំនួន ៥លីត្រ និង ស្ករ៥គ.ក

### វត្ថុធាតុផ្សំសម្រាប់លាមកសត្វ ១០០គ.ក

១. អង្កាមរស់ចំនួន៥០គ.ក

២. ក្បាលត្រី/ខ្យងមាស ចំនួន ២០គ.ក

៣. ធ្យូងអង្កាមចំនួន ៥០គ.ក

៤.លាមក មាន់/ទា/ គោចំនួន ១០០គ.ក

និងលាមកប្រចៀវចំនួន ២គ.ក

៥. កន្ទក់ចំនួន ២០គ.ក

៥.មេជីទឹកធម្មជាតិចំនួន ១លីត្រ និង ស្ករ១គ.ក

## ២. របៀបធ្វើ:

១. យកខ្យង/ក្បាលត្រី មកផ្អាប់ចំនួន ៧ថ្ងៃ ដោយស្រោចមេជីទឹកដែលផ្សំពីផ្លែឈើ។

២.យកខ្យង/ក្បាលត្រីដែលផ្អាប់រួចមកលាយច្របល់ជាមួយ អង្កាម កន្ទក់ ធ្យូងអង្កាម លាមកសត្វ និង លាមកប្រចៀវ លាយអោយសព្វ។

៣.យកមេជីធម្មជាតិចំនួន៥លីត្រ និង ស្ករចំនួន ៥គ.កលាយជាមួយទឹកទឹកធម្មតា ស្រោចលើគំនជី អោយមានសំណើម៥០%។

៣. ផ្អាប់ទុករយៈពេល រក្សាវាទុកនៅកន្លែងម្លប់ ពី ២០ទៅ៣០ថ្ងៃអាចយកទៅប្រើប្រាស់បាន។ ត្រូវច្របល់ជីក្នុង១អាទិត្យ១ដងដើម្បីអោយគំនជីកាច់បានល្អ និងឆាប់បានប្រើប្រាស់។

**រៀបចំដោយចងក្រង:** លោក. ឆាយ ម៉េង និង លោក ប៊ិន ច័ន្ទតូនី (០១០ ៧៨៩ ៣៦៥/០៦១ ៧៨៩ ៣៦៥)

E-mail: c.meng007@gmail.com

# ៣. របៀបប្រើ

## តាមរយៈបទពិសោធន៏ និង អនុវត្តន៏ជាក់ស្តែង ប្រើប្រាស់លើដំណាំ បន្លែ របស់

## នៅការិយាល័យអង្គការ ការីតាស ប្រចាំខេត្តកណ្តាល

**១. ដំណាំបន្លែ៖**

- (សណ្តែកគួ ត្រប់ ម្រះ ត្រសក់ និង បន្លែស្លឹក) ផ្ទៃដី ១មែត្រការ៉េប្រើប្រាស់ទ្រាប់បាត ១គ.ក មុនពេលដាំឬព្រួសគ្រាប់។
- *ជួយអោយដំណាំលូតលាស់ល្អ បង្កើនអតិសុខុមប្រាណក្នុងដី ធ្វើអោយបន្លែចាក់ឬសបានល្អ។*

## កំណត់ចំណាំ៖

- ចំពោះដំណាំបន្លែពេលទ្រាប់បាតជាមួយជីកំប៉ុស្ត នេះហើយ ត្រូវប្រើបជីផ្សំពីផ្លែឈើ និង ថ្នាំបណ្តេញសត្វល្អិត ពីរុក្ខជាតិ ដើម្បីជំរុញការ លូតលាស់របស់បន្លែ អោយមានសុខភាពល្អ និង មានទិន្នផលខ្ពស់។
- កំរិតនៃការប្រើប្រាស់ ជីនេះត្រូវប្រើប្រាស់រាល់លើក នៅពេលដំណាំ រាល់លើក ជី១គ.ក ក្នុង ផ្ទៃរង ១មែត្រការ៉េ។
- ចំពោះដំណាំស្រូវ ប្រើប្រាស់ជីកំប៉ុស្តិ៍នេះឆ្នាំ ទី១ចំនួន ១០០០គ.ក ក្នុង១ហ.ត និង នៅឆ្នាំទី២ ប្រើប្រាស់ចំនួណាន ៥០០គ.ក ក្នុង១ហាត ដើម្បីជំរុញអោយស្រូវបានការលូតលាស់ល្អ និង ទិន្នផលខ្ពស់ ត្រូវប្រើប្រាស់ជីកំប៉ុស្តទឹក ថ្នាំបណ្តេញសត្វល្អិត ជាប្រចាំ។

**រៀបចំដោយចងក្រង:** លោក. ឆាយ ម៉េង និង លោក ប៊ិន ច័ន្ទតូនី (០១០ ៧៨៩ ៣៦៥/០៦១ ៧៨៩ ៣៦៥)

E-mail: c.meng007@gmail.com